ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥២

ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២

សាលដីកា

លេខ ៣៨៧ VIII

ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

## ចៅក្រមរបាយការណ៍

ឯកឧត្តម [redacted]

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] សុគន្ធ និង... [redacted] វិបុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] វឌ្ឍនៈនារីរតន៍, បណ្តឹង... សាទុក្ខលេខ ៤០៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ហៀង, បណ្តឹងសាទុក្ខ... លេខ ៤២១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] រចនា និងបណ្តឹងសាទុក្ខលេខ ៤២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ប៊ុនធឿន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ...

Scanned with CamScanner

[redacted] សុផាយ និងឈ្មោះ [redacted] សុវណ្ណចរិយា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

- **បុគ្គលម្តឹងសាធុក្ខ** ជនជាប់ចោទ៖

១-ឈ្មោះ [redacted] **ចន្ទ្រនានារីរតន៍** ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបេឡាករផ្នែកទទួលប្រាក់ពន្ធ នៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងលំនៅឋានមុនពេល[redacted] ភូមិក្រាំងងួនតី សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោ[redacted] "រស់" ប្តីឈ្មោ[redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦១៤ "ណ" ង.ឃ.ង ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ នៅពន្ធនាគារព្រៃស ម២។

មេធាវីការពារសិទ្ធិ លោក[redacted] សុគន្ធ និង លោក [redacted] ទិបុល ។

២-ឈ្មោះ [redacted] **សុវណ្ណចរិយា** ភេទស្រី កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីត្រួតពិនិត្យផ្នែកទទួលប្រាក់ពន្ធ នៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិក្បាលហុង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ លំនៅឋានមុនពេលឃុំខ្លួននៅផ្ទះ[redacted] សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]ស់" ម្តាយឈ្មោះ [redacted] ស្លាប់" ប្តីឈ្មោ[redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៥៦ "ណ" ង.ឃ.ង ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ នៅពន្ធនាគារព្រៃស ម២។

មេធាវីការពារសិទ្ធិ លោក[redacted] ម៉ុនធឿន ។

៣-ឈ្មោះ [redacted] **រចនា** ភេទស្រី កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអនុប្រធានប្រតិបត្តិការស្នាក់ការកណ្តាលទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ និងគម្រោងរដ្ឋាភិបាលនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ លំនៅឋានមុនពេលឃុំខ្លួននៅ[redacted] សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោ[redacted] "ស្លាប់" ប្តីឈ្មោះ[redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៣២ "ណ" ង.ឃ.ង ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ នៅពន្ធនាគារព្រៃស ម២។

មេធាវីការពារសិទ្ធិ លោក[redacted] ម៉ុនរ៉ា ។



Scanned with CamScanner

៤-ឈ្មោះ [redacted] សុនាយ ភេទប្រុស ឆ្នាំកំណើត១៩៨៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីផ្នែកព័ត៌មានវិទ្យា (IT) និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារ នៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិ០១ ឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ លំនៅឋានមុនពេលឃុំខ្លួននៅ [redacted]ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោ[redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៥៧ "ណ" ង.ឃ.ង ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ នៅពន្ធនាគារព្រៃស ម១ ។

មេធាវីការពារសិទ្ធិ [redacted] ម៉ុនធឿន ។

ជាប់ចោទពីបទ **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត** ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

៥-ឈ្មោះ [redacted] ហៀង ភេទប្រុស កើតឆ្នាំ១៩៧៧ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបុគ្គលិកផ្នែកសន្តិសុខ និងបើកបររថយន្តនៅស្នាក់ការកណ្ដាលធនាគារកាណាឌីយ៉ា អ.ក ទីកន្លែងកំណើតនៅភូមិក្រាំងពង្រ ឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ ទីលំនៅមុនពេលឃុំខ្លួន[redacted]សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០១៤ "ណ" ង.ឃ.ង ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ នៅពន្ធនាគារព្រៃស ម១ ។

មេធាវីការពារសិទ្ធិ លោក[redacted]សម្បត្តិ និងកញ្ញ[redacted] គីមហេង ។

៦-ឈ្មោះ [redacted] ស៊ីមន្លា ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីនាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃនៅក្រសួងមុខងារសាធារណៈ ទីកន្លែងកំណើតនៅសង្កាត់អូរឫស្សីទី៣ ក្រុងភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន[redacted]មិក្រាំងដូនតី សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted] "រស់" ម្ដាយឈ្មោះ[redacted] "រស់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន។

មេធាវីការពារសិទ្ធិ លោក [redacted] សុគន្ធ និង លោ[redacted] ទិបុល



Scanned with CamScanner

ជាប់ចោទពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៨ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

- **បុគ្គលដែលបានប្រព្រឹត្តបទល្មើសមានការពាក់ព័ន្ធ ៖**

៧-ឈ្មោះ [redacted] បញ្ញាសុជាតា ភេទស្រី ឆ្នាំកំណើត១៩៨៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបុគ្គលិកនៅធនាគារវឌ្ឍនៈអាស៊ីចំកាត់ ទីកន្លែងកំណើតនៅសង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ លំនៅឋានមុនពេលឃុំខ្លួន[redacted] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]រស់” ម្តាយឈ្មោះ [redacted]រស់” ប្តីឈ្មោះ [redacted] “រស់” មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩១៣១ “ណ” ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ នៅពន្ធនាគារព្រៃស ម២ ។

ជាប់ចោទពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅចំណុចស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

- **ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ**

ធនាគារកាណាឌីយ៉ា ក.អ (CANADIA BANK PLC) មានអាសយដ្ឋានស្ថិតនៅអាគារលេខ ៣១៥ វិថីព្រះអង្គឌួងកែងនឹងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានលោក វ៉ាន់ ឆាវស៍ ជាអគ្គនាយករងប្រតិបត្តិធនាគារកាណាឌីយ៉ា អ.ក ជាអ្នកតំណាង ។

មេធាវីការពារសិទ្ធិ និងតំណាង លោក[redacted] មុះមុនី លោកស្រី[redacted] សុខកនិកា និងលោកស្រី [redacted]ាជ្រលក្ខិណា ។

**អំពីអង្គហេតុ ៖**

មុនពេលកើតហេតុឈ្មោះ [redacted] វឌ្ឍននារីរតន៍ ជាបុគ្គលិកនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា ក.អ ទទួលបន្ទុកផ្នែកបង់ប្រាក់ពន្ធជូនរដ្ឋពីអតិថិជន តាមរយៈការវេរចូលគណនីរបស់អគ្គនាយកដ្ឋានពន្ធដារ ហើយក្នុងរយៈពេលដែលបានទទួលតួនាទីនេះឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានធ្វើសកម្មភាពតែបំបាត់ប្រាក់របស់ធនាគារកាណាឌីយ៉ា ក.អ ជាច្រើនលើក ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ ឡៀង វឌ្ឍននារីរតន៍ បានធ្វើសកម្មភាពទៀត ដោយយកប្រាក់ចេញពីធនាគារកាណាឌីយ៉ា ក.អ ចំនួន ៦ ១៦០ ០០០$ (ប្រាំមួយលានដប់ប្រាំមួយម៉ឺនដុល្លាអាមេរិក) ច្រកក្នុងថង់ខ្មៅចំនួន ៣ថង់ ហើយបានហៅឈ្មោះ[redacted] បញ្ញាសុជាតា ដែលជា



Scanned with CamScanner

អតីតបុគ្គលិកធនាគារកាណាឌីយ៉ា ក.អ មកជួយនាំសន្តិសុខ ៣នាក់ ជញ្ជូនប្រាក់ទាំងនេះពីជាន់ផ្ទាល់ដីឡើងទៅជាន់ទី៥ នៃអាគារស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក រួចរង់ចាំនៅជាន់ទី៥ ប្រហែលកន្លះម៉ោងទើបឈ្មោះ [redacted] ស៊ីមន្តា ជាប្តីរបស់ឈ្មោ[redacted] វឌ្ឍនានារីរតន៍ មកដល់រួចជញ្ជូនថង់ប្រាក់ទាំងនេះដាក់ក្នុងរថយន្តហើយដឹកចេញទៅបាត់។ ក្នុងការប្រព្រឹត្តិរបស់ឈ្មោះ [redacted] វឌ្ឍនានារីរតន៍ នេះមានការសម្របសម្រួលពីឈ្មោះ [redacted]ហៀង ជាសន្តិសុខ និងជាអ្នកបើកបររថយន្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផងដែរ ដោយឈ្មោះ [redacted] ហៀង នេះបានជួយលីថង់ប្រាក់ពីជាន់ផ្ទាល់ដីទៅកាន់ជាន់ទី៥ នៃអាគារកណ្តាលធនាគារកាណា-ឌីយ៉ា អ.ក។ រីឯឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] រចនា ជាបុគ្គលិកមានតួនាទីត្រួតពិនិត្យការងាររបស់ឈ្មោះ [redacted] វឌ្ឍនានារីរតន៍ ដោយផ្ទាល់នោះបានឃុបឃិតគ្នាមិនរាយការណ៍ជូនថ្នាក់គ្រប់គ្រងធនាគារឡើយ ដោយឈ្មោះ [redacted] សុវណ្ណចរិយា បានទទួលប្រាក់ពីឈ្មោះ[redacted] វឌ្ឍនានារីរតន៍ រួចយកទុកក្នុងថតតុរបស់ខ្លួនរហូតដល់ចប់ម៉ោងធ្វើការក៏យកប្រាក់នេះដាក់ចូលកាបូបរបស់ខ្លួន រួចចេញទៅផ្ទះដោយមានឈ្មោះ [redacted] ស៊ីមន្តា ជាប្តីបានមកទទួល។ ក្នុងការប្រព្រឹត្តនេះឈ្មោះ[redacted]ញាសុជាតា ជាអ្នកសហការប្រព្រឹត្តយ៉ាងសកម្ម និងជាអ្នកយកប្រាក់ដុល្លាអាមេរិកដែលឈ្មោះ [redacted] វឌ្ឍនានារីរតន៍ បានកិបកេងបានសម្រេចនោះទៅប្តូរជាប្រាក់រៀលវិញ។ លុះដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ ខាងធានាគារកាណាឌីយ៉ា អ.ក បានស្រាវជ្រាវរកឃើញថាឈ្មោះ[redacted]វឌ្ឍនានារីរតន៍ បានកៃបំបាត់ប្រាក់របស់ធនាគារកាណាឌីយ៉ា អ.ក ជាច្រើនលើកទើបខាងធនាគារដាក់ពាក្យបណ្តឹងអ្នកទាំង០២នាក់ ប្តីប្រពន្ធខាងលើ ហើយសមត្ថកិច្ចបានឃាត់ខ្លួនអ្នកទាំង ០២ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី និងបានប្តឹងបន្តពួកជាបន្តបន្ទាប់។

- **បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ មកជាបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោស៖

ក-ឈ្មោះ[redacted] វឌ្ឍនានារីរតន៍ ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] រចនា ភេទស្រី អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ



Scanned with CamScanner

គ-ឈ្មោះ [redacted] សុវណ្ណចរិយា ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ

ឃ-ឈ្មោះ [redacted] សុអាយ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ដាក់ទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤ឆ្នាំ (បួនឆ្នាំ) ពីបទ រំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៣-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] បញ្ញាសុជាតា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] ស៊ីមន្តា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ

ដាក់ទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤ឆ្នាំ (បួនឆ្នាំ) ពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៤-ផ្តន្ទាទោសឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ ដាក់ទោសពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ និង ០៦ខែ (បីឆ្នាំ និងប្រាំមួយខែ) ពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ប្រព្រឹត្តនៅស្នាក់ការកណ្តាលធនាគារកាណាឌីយ៉ា អ.ក ផ្លូវព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

៥-ឱ្យឈ្មោះ [redacted] វឌ្ឍនទារីរតន៍, ឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] សុវណ្ណចរិយា, ឈ្មោះ [redacted] សុអាយ, ឈ្មោះ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ស៊ីមន្តា និងឈ្មោះ [redacted] ហៀង រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០០ ០០០ ០០០៛ (ប្រាំរយលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ធនាគារកាណាឌីយ៉ា អ.ក ដែលមានលោក [redacted] ផារស៍ ជាតំណាង តាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-វត្ថុតាងចាប់យកមាន៖

ក-រឹបអូសជាសម្បត្តិរដ្ឋនូវ ៖

ក-១.រថយន្តម៉ាក TOYOTA HIGHTLANDER ពណ៌ស ស៊េរីឆ្នាំ២០០៩ ពាក់ផ្លាកលេខភ្នំពេញ ២BF-៣៣៨៣ ចំនួន ០១គ្រឿង ។

ក-២.ទូរស័ព្ទដៃម៉ាក NOKIA (ចុចពិល) ពណ៌ខ្មៅ (មិនដំណើរការ) ចំនួន ០១គ្រឿង ។

ខ-ប្រគល់ឱ្យម្ចាស់ដើមយកទៅប្រើប្រាស់ជាកម្មសិទ្ធិនូវ បន្ទះស៊ីឌីចំនួន ០១បន្ទះ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍, ឈ្មោះ[redacted] រចនា, ឈ្មោះ [redacted]សុវណ្ណចរិយា, ឈ្មោះ[redacted]ុឆាយ, ឈ្មោះ[redacted]បញ្ញាសុជាតា, ឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោ[redacted]ហៀង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

- **បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ៣៤៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់លោក [redacted] សុគន្ធ និងលោក[redacted] វិបុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោ[redacted] វឌ្ឍននារីរតន៍ , បណ្តឹងឧទ្ធរណ៍លេខ ៣៤២ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោ[redacted] រចនា, បណ្តឹងឧទ្ធរណ៍លេខ ៣៥១ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]បញ្ញាសុជាតា, បណ្តឹងឧទ្ធរណ៍លេខ ៣៤៦ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]ហៀង, បណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់លោក [redacted] ប៊ុនធឿន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]សុឆាយ និងឈ្មោះ[redacted]សុវណ្ណចរិយា និងបណ្តឹងឧទ្ធរណ៍លេខ ៣៥៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted] ចាន់ស្រីយ៉ា និងឈ្មោះ[redacted]ហៀង ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

- **បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៤៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោ[redacted]សុគន្ធ និងលោក [redacted] វិបុល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted]វឌ្ឍននារីរតន៍, បណ្តឹងឧទ្ធរណ៍លេខ ៣៤២ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោ[redacted]រចនា,បណ្តឹងឧទ្ធរណ៍លេខ ៣៥១ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]ញ្ញាសុជាតា, បណ្តឹងឧទ្ធរណ៍លេខ ៣៤៦ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]ហៀង ,បណ្តឹងឧទ្ធរណ៍លេខ ៣៦១ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ របស់លោ[redacted]ប៊ុនធឿន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុឆាយ និងឈ្មោះ [redacted]សុវណ្ណចរិយា, បណ្តឹងឧទ្ធរណ៍លេខ ៣៥៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ស្រីយ៉ា និងឈ្មោះ[redacted]ហៀង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។



Scanned with CamScanner

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា ,ឈ្មោះ [redacted] វឌ្ឍននារីរតន៍ ,ឈ្មោះ [redacted] រចនា , ឈ្មោះ [redacted] បញ្ញាសុជាតា ,ឈ្មោះ [redacted] ហៀង ,ឈ្មោះ [redacted] សុឆាយ និងឈ្មេ [redacted] សុវណ្ណចរិយា តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា ,ឈ្មោ [redacted] វឌ្ឍននារីរតន៍ , ឈ្មោ [redacted] រចនា , ឈ្មោះ [redacted] បញ្ញាសុជាតា ,ឈ្មោះ [redacted] ហៀង ,ឈ្មោះ [redacted] សុឆាយ និងឈ្មោះ [redacted] សុវណ្ណចរិយា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ ។

- **បានឃើញ** បណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] សុគន្ធ និងលោក [redacted] វិបុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] វឌ្ឍននារីរតន៍, បណ្តឹងសាទុក្ខលេខ ៤២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ប៊ុនធឿន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុឆាយ និងឈ្មោះ [redacted] សុវណ្ណចរិយា, បណ្តឹងសាទុក្ខលេខ ៤០៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោ [redacted] ហៀង និងបណ្តឹងសាទុក្ខលេខ ៤២១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] រចនា ក្នុងការប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានឡើងធ្វើសេចក្តីរាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានកែបំបាត់ប្រាក់ធនាគារកាណាឌីយ៉ា ជាច្រើនលើក និងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ ជនជាប់ចោទរូបនេះបានធ្វើសកម្មភាពទៀត ដោយមានការសហការពីជនជាប់ចោទឈ្មោះ [redacted] រចនា,ឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] សុឆាយ និងមានការជួយសម្រួលពីជនជាប់ចោទឈ្មោ [redacted] បញ្ញាសុជាតា, ឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោះ [redacted] ហៀង បានយកប្រាក់ចេញពីធនាគារចំនួន ៦ ១៦០ ០០០$ (ប្រាំមួយលានមួយសែនប្រាំមួយម៉ឺន) ដុល្លារអាមេរិក។ សារណារបស់ជនជាប់ចោទឈ្មោ [redacted] វឌ្ឍននារីរតន៍ [redacted] រចនា [redacted] សុវណ្ណចរិយា, [redacted] សុឆាយ, [redacted] ស៊ីមន្ថា និងឈ្មោ [redacted] ហៀង ពុំមានមូលហេតុដូចបានបញ្ញត្តិក្នុងមាត្រា ៤១៩ នៃក្រមព្រហ្មទណ្ឌឡើយ គប្បីបដិសេធចោល។ សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតាមច្បាប់។

+លោក [redacted] សុគន្ធ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា និងឈ្មោ [redacted] វឌ្ឍននារីរតន៍ បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] វឌ្ឍននារីរតន៍ ជាអ្នកធ្វើការនៅផ្នែកធនាគារកាណាឌីយ៉ា ចំណែកឈ្មោះ [redacted] ស៊ីមន្ថា ត្រូវជាប្តីរបស់គាត់ធ្វើការនៅក្រសួងមុខងារសាធារណៈ នៅថ្ងៃទី១៨



Scanned with CamScanner

ខែមករា ឆ្នាំ២០២០ មានអតិថិជនបានយកប្រាក់ចំនួន ៦ ១៦០ ០០០$ ដើម្បីដាក់ចូលក្នុងគណនេយ្យពន្ធដារតាមរយៈធនាគារកាណាឌីយ៉ា ក្រោយពីបានទទួលប្រាក់ពីអតិថិជនរួច ឈ្មោះ [redacted]វឌ្ឍននារីរតន៍ បានដាក់ចូលនៅក្នុងថង់ខ្មៅ និងបានហៅប្ដីឱ្យមកយកខ្លួន ក្នុងគោលបំណងយកប្រាក់នោះដូរជាប្រាក់រៀលនៅលីហ្សួរ ដើម្បីបានចំណេញ ។ ក្រោយមកខាងពន្ធដារបានសួរទៅធនាគារថា មិនឃើញប្រាក់ចូលក្នុងគណនេយ្យ ទើបខាងធនាគារធ្វើការសួរនាំកូនក្ដីខ្លួនរឿងប្រាក់នោះថា បានប្ដូរតែជាង ៥លានដុល្លារ ដោយសារពេលនោះអត្រាប្ដូរប្រាក់រៀលមានការឡើងថ្លៃ និងបានឱ្យឈ្មោះ សុជាតា ដាក់បញ្ចូលក្នុងគណនេយ្យសិន ចំណែកប្រាក់ដែលនៅសល់គាត់បានយកទៅដាក់ក្នុងគណនេយ្យពន្ធដារគ្រប់ចំនួនអស់ហើយ។ ចំណែកកូនក្ដីខ្លួនឈ្មោ[redacted] ស៊ីមន្ថា វិញមិនបានទាក់ទងក្នុងរឿងនេះទេ គាត់ត្រូវបានតុលាការចោទប្រកាន់ពីបទ រំលោភលើទំនុកចិត្ត ហើយគាត់ក៏បានដាក់ពាក្យសុំនៅក្រៅឃុំជាបណ្ដោះអាសន្ន នៅសាលាដំបូង និងសាលាឧទ្ធរណ៍បានបដិសេធពាក្យសុំនោះចោល តែមកដល់តុលាការកំពូលបានអនុញ្ញាតឱ្យកូនក្ដីខ្លួនឈ្មោះ [redacted]ស៊ីមន្ថា នៅក្រៅឃុំជាបណ្ដោះអាសន្ន ប៉ុន្តែដោយនៅមានបទល្មើសផ្សេងទៀតទើបត្រូវបានចាប់ខ្លួនវិញ។ កូនក្ដីខ្លួនទាំងពីរនាក់មានកូនតូចៗគ្មានអ្នកចិញ្ចឹមបីបាច់ថែរក្សានោះទេ។ កូនក្ដីខ្លួនឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានយកប្រាក់ទៅដាក់ក្នុងគណនេយ្យពន្ធដារគ្រប់ចំនួនហើយ ចំណែកខាងពន្ធដារក៏បានទទួលស្គាល់ថាគ្រប់ចំនួនហើយដែរ ដូចនេះពុំមានព្យសនកម្មពីបទល្មើសព្រហ្មទណ្ឌឡើយ ទង្វើកូនក្ដីខ្លួនគ្រាន់តែខុសនឹងបទបញ្ជាផ្ទៃក្នុងរបស់ធនាគារដែលហាមមិនឱ្យយកប្រាក់ចេញពីធនាគារតែប៉ុណ្ណោះ ប្រសិនបើកូនក្ដីខ្លួនជាប់ពន្ធនាគារទាំងពីរនាក់គ្មានអ្នកណាមើលថែទាំកូនទេ ។

សំណូមពរ សូមតុលាការសម្រេចឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទ តាមមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមិនបាច់បង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ។

+លោក[redacted]វិបុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ស៊ីមន្ថា និងឈ្មោះ [redacted]ឌ្ឍននារីរតន៍ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ខ្លួនសូមឯកភាពទាំងស្រុងចំពោះសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីសហភាគា។ កូនក្ដីខ្លួនឈ្មោះ [redacted] ស៊ីមន្ថា ត្រូវបានតុលាការកំពូលសម្រេចក្នុងសំណុំរឿងមុនអង្គសេចក្ដីតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៦៤ II ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ ក្នុងសំអាងហេតុត្រង់ចំណុចទី៣ និងទី៤ បញ្ជាក់ថា កូនក្ដីខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ឡើយ ទើបតុលាការកំពូលសម្រេចឱ្យកូនក្ដីខ្លួននៅក្រៅឃុំជាបណ្ដោះអាសន្ន។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទ។

+លោក [redacted] ប៊ុនធឿន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]សុវណ្ណចរិយា និងឈ្មោះ [redacted]សុឆាយ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ដូចសហភាគាបានលើកឡើងខាងដើមថា លុយដែលបាត់ចំនួន ៦ ១៦០ ០០០ ដុល្លារអាមេរិក នោះ ត្រូវបានបង្វិលចូលក្នុងគណនេយ្យពន្ធដារគ្រប់ចំនួនហើយ ស្របទៅតាមការអះអាងរបស់ធនាគារផងដែរ ដូច្នេះព្យសនកម្មក៏គ្មានដែរ។ កូនក្ដីខ្លួនឈ្មោះ [redacted]សុវណ្ណចរិយា គ្រាន់តែជា



Scanned with CamScanner

មន្ត្រីត្រួតពិនិត្យ ដើមបណ្ដឹងរដ្ឋប្បវេណីក៏គ្មានភស្តុតាងណាមួយជាក់លាក់ ដែលធ្វើការចោទប្រកាន់មកលើកូនក្ដីខ្លួនថា បានប្រព្រឹត្តនោះដែរ។ ពាក់ព័ន្ធនឹងសំអាងហេតុរបស់សាលាដំបូងគឺមិនមានភាពស៊ីសង្វាក់គ្នាឡើយ ដោយក្នុងសំអាងហេតុចំណុចទី២៦ នៃសាលក្រមសាលាដំបូងកូនក្ដីខ្លួនឆ្លើយថា ពុំបានដឹងពីការបាត់បង់ប្រាក់នេះទេ ហើយចម្លើយនេះស្របទៅនឹងចម្លើយរបស់ឈ្មោះ [redacted] វឌ្ឍនទារីរតន៍ ក្នុងសំអាងហេតុចំណុចទី២៧ នៃសាលក្រមថា ពុំមានការសហការគ្នាដើម្បីយកលុយនោះចេញដែរ។ ការដែលកូនក្ដីខ្លួនមិនបានដឹងទេ ព្រោះលុយនោះមិនបានឆ្លងកាត់ប្រព័ន្ធរបស់ធនាគារទេ។ ចំពោះកូនក្ដីខ្លួនឈ្មោះ [redacted] សុឆាយ ទៀតសោត គឺគ្មានភស្តុតាងដាក់បន្ទុកសូម្បីតែបន្តិច ព្រោះគាត់គ្រាន់តែជាមន្ត្រី IT ធម្មតាប៉ុណ្ណោះ លុះត្រាតែមានការស្នើសុំពីភាគីពាក់ព័ន្ធខាងក្រោម ឬផ្នែកបច្ចេកទេសផ្សេងៗទើបគាត់អាចបើកមើលបាន ។ ធនាគារកាណាឌីយ៉ាតែងតែធ្វើសវនកម្មជារៀងរាល់ឆ្នាំ ហើយពុំបានបង្ហាញពីការបាត់ប្រាក់នោះទេ។ ក្នុងសារណាការពារខ្លួនបានភ្ជាប់ជាមួយនូវភស្តុតាងផ្សេងៗ ដើម្បីជូនតុលាការដើម្បីពិនិត្យពិចារណា។

សំណូមពរ សូមតុលាការសម្រេចឱ្យកូនក្ដីខ្លួនឈ្មោះ [redacted] សុវណ្ណចរិយា និងឈ្មោះ [redacted] សុឆាយ រួចផុតពីបទចោទប្រកាន់ តាមមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមិនបង្ខិល។

+ជនជាប់ចោទឈ្មោះ [redacted]ុវណ្ណចរិយា បានឆ្លើយថា៖ ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យខ្លួន។ សូមតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

+ជនជាប់ចោទឈ្មោះ [redacted] សុឆាយ បានឆ្លើយថា៖ ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យខ្លួន។

+លោក [redacted] ប៊ុនវ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រចនា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ក្នុងរឿងនេះការចោទប្រកាន់មកលើកូនក្ដីខ្លួនពីបទ សមគំនិត ដោយសារគាត់ជាអនុប្រធានទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធហើយពាក្យបណ្ដឹងគ្រប់ដំណាក់កាលទាំងអស់មេធាវីរបស់ធនាគារ គឺពុំបានប្ដឹងចំឈ្មោះកូនក្ដីខ្លួននោះទេ ។ អង្គហេតុដែលកើតឡើងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជាថ្ងៃដែលកូនក្ដីខ្លួនបានសុំច្បាប់ឈប់សំរាក និងតាមការសួរបញ្ជាក់ពីមេធាវីតំណាងឱ្យធនាគារថា កូនក្ដីខ្លួនឈ្មោះ [redacted] រចនា ពិតជាបានសុំច្បាប់ឈប់សម្រាកពិតប្រាកដមែន។ ក្នុងអង្គហេតុនេះតាំងពីដំណាក់កាលសាលាដំបូង រហូតមកដល់សាលាឧទ្ធរណ៍កូនក្ដីខ្លួនពុំបានពាក់ព័ន្ធក្នុងបទល្មើសនេះទេ ហើយរាល់ចម្លើយសារភាពរបស់ជនជាប់ចោទដែលពាក់ព័ន្ធទាំងអស់ក៏មិនបានឆ្លើយដាក់កូនក្ដីខ្លួនដែរ។ តាមមាត្រា ២៩ អំពីបទសមគំនិតក្នុងខ្លឹមសារនេះបានបញ្ជាក់អំពីការជួយសម្របសម្រួល ជួយជាមធ្យោបាយ ឬទទួលផលប្រាក់ចំណេញ តែកូនក្ដីខ្លួនពុំបានផ្សំគំនិតដូចក្នុងមាត្រានេះទេ គឺមានន័យថា ក្រោយពីបានដឹងបញ្ហានេះភ្លាម កូនក្ដីខ្លួនបានឆោរឡោ ក្នុងនាមគាត់គឺជាប្រធានគ្រប់គ្រង។ កូនក្ដីខ្លួនមានតួនាទីត្រួតពិនិត្យទៅលើកូនចៅគាត់ពេលដែលទទួលប្រាក់ពីអតិថិជនរួច ត្រូវបញ្ចូលប្រាក់ទាំងអស់ចូលទៅក្នុងប្រព័ន្ធរបស់ធនាគារកាណាឌីយ៉ា នោះទើបកូនក្ដីខ្លួនអាចត្រួតពិនិត្យក្នុងប្រព័ន្ធបាន ។



Scanned with CamScanner

កូនក្តីខ្លួនមានតែធ្វើការលួងលោមឈ្មោះ [redacted] វឌ្ឍននារីរតន៍ ទៅវិញទេ ដើម្បីឱ្យឈ្មោះនេះយកប្រាក់ទាំងអស់មកដាក់ក្នុងធនាគារគ្រប់ចំនួនវិញ ក្នុងនាមកូនក្តីខ្លួនជាប្រធាន ។

សំណូមពរ សូមតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

+ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា ខ្លួនសូមឯកភាពតាមការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យខ្លួន ។ នៅថ្ងៃកើតហេតុនោះខ្លួនពិតជាបានសុំច្បាប់ឈប់សំរាកពិតប្រាកដមែន ក្រោយពីបានដឹងពីការបាត់ប្រាក់ពីធនាគារហើយ ខ្លួនក៏បានព្យាយាមលួងលោមឱ្យឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដើម្បីយកប្រាក់មកដាក់ចូលធនាគារគ្រប់ចំនួនវិញ ទើបខ្លួនរាយការណ៍ទៅកាន់ថ្នាក់លើតាមក្រោយ បែរជាមកចោទប្រកាន់ខ្លួនអំពីបទសមគំនិតនេះទៅវិញ។ ខ្លួនធ្វើការអស់រយះពេល ១៥ឆ្នាំហើយ បើខ្លួនមានគំនិតទុច្ចរិតមិនមែនខ្លួនអាចធ្វើការដល់សព្វថ្ងៃនេះទេ

+កញ្ញា [redacted] គឹមហេង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហៀង បានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនជាបុគ្គលិកសន្តិសុខ និងបើកបររថយន្តនៅធនាគារកាណាឌីយ៉ា តាំងពីឆ្នាំ២០០២មកម្ល៉េះ។ នៅក្នុងកំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានអះអាងថា កូនក្តីរបស់ខ្លួនមិនបានពាក់ព័ន្ធនឹងរឿងនេះទេ ហើយកំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] បញ្ញាសុជាតា ក៏បានអះអាងថា កូនក្តីរបស់ខ្លួនមិនមានពាក់ព័ន្ធនឹងរឿងក្តីនេះដែរ។ កូនក្តីខ្លួនរួមទាំងសន្តិសុខ២នាក់ទៀត ជួយលើកជញ្ជូនឥវ៉ាន់តាមការពឹងពាក់ពីបុគ្គលិករបស់ធនាគារ គាត់ពុំមានសិទ្ធិសួរនាំថា ក្នុងថង់ទាំងបីនោះជាអ្វីដែរ ព្រោះថាធនាគារគឺជាកន្លែងលាក់ការសម្ងាត់បំផុត។ ដូច្នេះ ការចោទប្រកាន់មកលើកូនក្តីខ្លួនពីបទ សមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត គឺជាការចោទប្រកាន់ដោយគ្មានទឡ្ហីករណ៍ណាមួយឡើយ។ យោងតាមមាត្រា ៤ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថា ពុំមានបទល្មើសទេបើគ្មានចេតនាប្រព្រឹត្ត មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិថា វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

+លោក [redacted] បុរមុនី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធនាគារកាណាឌីយ៉ា ក.អ តំណាងដោយលោក [redacted] ឆារស៍ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ មានចេតនាគិតទុកជាមុនរួចហើយ ដើម្បីយកប្រាក់ចេញពីធនាគារ ទោះបីដឹងថា ខុសនឹងគោលការណ៍ផ្ទៃក្នុងរបស់ធនាគារក៏ដោយ។ ការបង់ពន្ធមិនតម្រូវឱ្យអតិថិជនយកប្រាក់សុទ្ធមកបង់ជាមួយធនាគារនោះទេ ដោយអតិថិជនអាចយកមូលប្បទានបត្រមកបង់ក៏បានដែរ ដើម្បីផ្តល់ភាពងាយស្រួលជូនអតិថិជន និងធានាសុវត្ថិភាពផងដែរ។ ប៉ុន្តែជនជាប់ចោទរូបនេះ បែរជាឲ្យអតិថិជនដកយកប្រាក់សុទ្ធពីគណនីមកបង់ពន្ធ រហូតដល់ទៅ ៦ ១៦០ ០០០$ ដែលដាក់ក្នុងថង់ខ្មៅចំនួនបី ត្រង់ចំណុចនេះបញ្ជាក់ថា ការដកជាប្រាក់សុទ្ធដើម្បីយកមកបង់ពន្ធបែបនេះ មិនមានភាពចាំបាច់ទាល់តែសោះចំពោះធនាគារ។ ជនជាប់ចោទអះអាងថា ខ្លួនយកប្រាក់នេះចេញ



Scanned with CamScanner

ទៅដូរនៅ លីហ្សូរ ដើម្បីបានចំនេញក្បាលកាក់ ឬចំណេញការប្រាក់ជាដើម ការអះអាងបែបនេះមិនមែនជារឿងត្រឹមត្រូវនោះទេ ហើយក៏មិនសមហេតុសមផលដែរ ព្រោះវាគ្រាន់តែជាលេសមួយដើម្បីរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ផ្ទុយទៅវិញ ជនជាប់ចោទមានគោលបំណងយកប្រាក់នេះ ដើម្បីប្រើប្រាស់ជាផលប្រយោជន៍ផ្ទាល់ខ្លួន។ ដោយហេតុថា នៅពេលយកប្រាក់ចេញពីធនាគារភ្លាម ជនជាប់ចោទមិនបានយកប្រាក់នោះទៅដូរនៅលីហ្សូរ ភ្លាមទេ បែរជាយកប្រាក់នោះទុកក្នុងរថយន្តរបស់ខ្លួនចាប់ពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ រហូតដល់មានការជូនដំណឹងពីអគ្គនាយកដ្ឋានពន្ធដារ និងរដ្ឋាករមកធនាគារលើចំនួនទឹកប្រាក់ដែលបាត់បង់ ហើយធនាគារបានធ្វើការទាក់ទងទៅខ្លួន ទើបជនជាប់ចោទខ្នះខ្នែងយកប្រាក់នោះទៅដូរ ហើយយកមកទូទាត់សងធនាគារវិញ។ ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្ថា បានអះអាងថា នៅពេលខ្លួនលើកប្រាក់ទាំងបីថង់ ចេញពីធនាគារទៅដាក់ក្នុងរថយន្តរបស់ខ្លួន ខ្លួនមិនបានដឹងថាក្នុងថង់នោះជាអ្វី ការអះអាងនេះមិនគួរឲ្យជឿឡើយ ខ្លួនបានដឹងច្បាស់ថាក្នុងថងនោះគឺជាប្រាក់សុទ្ធ ហើយក៏ជាប្រាក់សម្រាប់បង់ពន្ធអោយធនាគារដែរ។ ជនជាប់ចោទរូបនេះមិនមែនជាបុគ្គលិកធនាគារទេមិនមានសិទ្ធិចេញចូលក្នុងបរិវេណរបស់ធនាគារឡើយ តែបែរជាហ៊ានចូលក្នុងបរិវេណធនាគារដោយគ្មានការអនុញ្ញាត ថែមទាំងហ៊ានចូលយកប្រាក់ក្នុងបន្ទប់ប្រជុំរបស់ធនាគារទៀតផង។ ជនជាប់ចោទឈ្មោះ [redacted] សុណ្ណចរិយា បានអះអាងថា ខ្លួនមិនបានដឹងពីការបាត់ប្រាក់នេះទេព្រោះជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនទាវីរតន៍ មិនបានដាក់ប្រាក់នេះចូលប្រព័ន្ធធនាគារ នេះគ្រាន់តែជាការដោះសាររបស់ជនជាប់ចោទតែប៉ុណ្ណោះ ផ្ទុយទៅវិញ ជនជាប់ចោទរូបនេះបានឃុបឃិតជាមួយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍនទាវីរតន៍ ដើម្បីលួចយកប្រាក់នោះចេញពីធនាគារ ក្នុងនាមខ្លួនជាមន្ត្រីត្រួតពិនិត្យការងារប្រចាំថ្ងៃ និងជាប្រធានរបស់ជនជាប់ចោទឈ្មោ[redacted] វឌ្ឍនទាវីរតន៍ ពិតជាបានដឹងអំពីប្រតិបត្តិការការងារប្រចាំថ្ងៃ ហើយក៏បានដឹងច្បាស់អំពីការបាត់ប្រាក់នេះដែរ។ ជនជាប់ចោទឈ្មោះ [redacted]ចនា ជាប្រធានគ្រប់គ្រងការិយាល័យទទួលប្រាក់ពន្ធ នៅពេលទទួលបានព័ត៌មានពីការបាត់ប្រាក់ពន្ធមិនមានចូលក្នុងគណនីពន្ធដារ បែរជាទាក់ទងស្ងាត់ៗទៅឈ្មោះ [redacted]ឍ្ឍនទាវីរតន៍ ដោយមិនរាយការណ៍ភ្លាមៗទៅថ្នាក់ដឹកនាំធនាគារឡើយ សកម្មភាពនេះបង្ហាញថា ជនជាប់ចោទរូបនេះមានបំណងលាក់បាំងព័ត៌មានពីការបាត់ប្រាក់ពន្ធខាងលើ។ ការលាក់បាំងនេះច្បាស់ណាស់ថា បុគ្គលរូបនេះបានទទួលផលប្រយោជន៍ពីឈ្មោ[redacted] វឌ្ឍនទាវីរតន៍ ។ ជនជាប់ចោទឈ្មោះ [redacted]បុឆាយ មានតួនាទីប្រធានក្រុមប្រព័ន្ធស្នូលផ្នែកព័ត៌មានវិទ្យានៃធនាគារបានយល់ និងដឹងច្បាស់អំពីប្រព័ន្ធគ្រប់គ្រងក្នុងធនាគារ ជាពិសេសការងារប្រតិបត្តិការបង់ពន្ធនៅការិយាល័យបង់ពន្ធ។ ជនជាប់ចោទធ្លាប់បានចេញចូលជាញឹកញាប់នៅក្នុងការិយាល័យបង់ពន្ធ ហើយក៏ធ្លាប់ពិនិត្យមើលប្រព័ន្ធបង់ពន្ធដែរនៅពេលប្រព័ន្ធមានការរអាក់រអួល ដូច្នេះខ្លួនស្គាល់ច្បាស់ពីប្រតិបត្តិការបង់ពន្ធ និងស្គាល់ពីកង្វះខាត ចន្លោះប្រហោងក្នុងប្រតិបត្តិការបង់ពន្ធ ដែលអាចលួចយកប្រាក់ពន្ធបាន ជាពិសេសការបោះពុម្ពបង្កាន់ដៃបង់ពន្ធ និងការមិនដាក់ប្រាក់ចូលក្នុងគណនីពន្ធដារនៅធនាគារជាដើម។ ចំណែកជនជាប់ចោទឈ្មោះ [redacted] ហៀង ខ្លួនដឹងច្បាស់ណាស់ថា ថង់ខ្មៅដែលខ្លួនលើកពីបន្ទប់ប្រជុំ (VIP) ជាន់ផ្ទាល់ដីទៅជាន់ទី៥ គឺជាប្រាក់ ប៉ុន្តែបែរជាមិនរាយការណ៍អំពី



Scanned with CamScanner

ប្រាក់នោះទៅថ្នាក់ដឹកនាំ ឬប្រធានសន្តិសុខធនាគារឱ្យបានដឹងឡើយ ជនជាប់ចោទរូបនេះបានឃុបឃិតជាមួយនឹងជនជាប់ចោទផ្សេងទៀត និងបានទទួលផលប្រយោជន៍ក្នុងអំពើនេះ។ សរុបមកសកម្មភាពទាំងអស់នេះបញ្ជាក់ថា ជនជាប់ចោទបានរួមគ្នាប្រព្រឹត្តបទល្មើសលួចយកប្រាក់ពន្ធពីធនាគារ ហើយអំពើនេះធ្វើឱ្យខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។

សំណូមពរ សូមតុលាការសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

+លោកស្រី [redacted]ពជ្រលក្ខិណា ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធនាគារកាណាឌីយ៉ា ក.អ តំណាងដោយលោក [redacted] ឆារស់ បានលើកឡើងថា ខ្លួនសូមឯកភាពទាំងស្រុងទៅលើសេចក្តីសន្និដ្ឋានការពាររបស់មេធាវីសហភាគា។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៩៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់លោ[redacted]សុគន្ធ ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទ [redacted] ស៊ីមន្តា និងឈ្មោះ [redacted] វឌ្ឍននារីរតន៍ ក្នុងការប្តឹងសាទុក្ខ, បណ្តឹងលេខ ៤២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ប៊ុនធឿន ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] សុឆាយ និងឈ្មោះ[redacted]សុវណ្ណចរិយា ក្នុងការប្តឹងសាទុក្ខ, បណ្តឹងសាទុក្ខលេខ ៤០៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]ហៀង និងបណ្តឹងសាទុក្ខលេខ ៤២១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]រចនា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ ,មាត្រា ៤១៨, មាត្រា ៤២០ និងមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ទោះបីជាអវត្តមានជនជាប់ចោទឈ្មោះ[redacted]វឌ្ឍននារីរតន៍ និងឈ្មោះ[redacted] ឆារស់ ជាអ្នកតំណាងឱ្យធនាគារនាពេលសវនាការក្តី ក៏សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាចបន្តនីតិវិធីបាន ពីព្រោះថា តុលាការកំពូលនាពេលនេះពិនិត្យពិចារណាតែលើអង្គច្បាប់ប៉ុណ្ណោះ ហើយក៏ពុំចាំបាច់ស្តាប់ចម្លើយភាគីដែរ



Scanned with CamScanner

ដោយផ្អែកតាមបញ្ញត្តិមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ម្យ៉ាងទៀត មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក៏មានវត្តមានហើយដែរ ។

៣-យល់ឃើញថា មូលហេតុនៃបណ្តឹងសាទុក្ខក្នុងសារណាការពារ និងតាមខ្លឹមសារនៃសារណាតប ព្រមទាំងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនាពេលសវនាការ តុលាការកំពូលពិចារណាឃើញថា ៖

ក-ការដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានលើកថា ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ បានចូលបម្រើការងារជាបុគ្គលិកធនាគារកាណាឌីយ៉ា តាំងពីឆ្នាំ២០១៥ នៅឆ្នាំ២០១៧ ជាអ្នកទទួលបន្ទុកសម្របសម្រួលជាមួយមន្ត្រីពន្ធដារ និងអតិថិជនយកប្រាក់មកបង់ពន្ធជូនរដ្ឋ ។ នៅអំឡុងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ជនជាប់ចោទបានយកប្រាក់ពីអតិថិជនមកបង់ចំនួន ៦ ០០០ ០០០ (ប្រាំមួយលាន)ដុល្លារអាមេរិក ទៅចាត់ចែងប្តូរយកប្រាក់រៀលខាងក្រៅធនាគារចង់បានចំណេញក្បាលកាក់បន្តិចបន្តួច ។ ការយកប្រាក់ទៅប្តូរជាប្រាក់រៀលនៅខាងក្រៅមិនទទួលខុសត្រូវចំពោះច្បាប់ព្រហ្មទណ្ឌដូចដែលតំណាងអយ្យការចោទប្រកាន់នឹងត្រូវជាប់ពន្ធនាគារទេ គឺទទួលខុសទៅនឹងគោលការណ៍របស់ធនាគារដែលត្រូវអនុវត្តពិន័យប៉ុណ្ណោះ ។ ម្យ៉ាងទៀតប្រាក់ត្រូវជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ប្តូរជាប្រាក់រៀលសងធនាគារគ្រប់ចំនួនហើយ ដូចដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ថា បានសងរួចរាល់ដែរ ។ ផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ មាត្រា ៣៥០ , មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌវិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ ។ ដូច្នេះសំណូមពរឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។ មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបវិញថា ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ជាបុគ្គលិកធនាគារកាណាឌីយ៉ា ក.អ មានតួនាទីសំខាន់ផ្នែកទទួលប្រាក់បង់ពន្ធជូនរដ្ឋតាមរយៈធនាគារចូលក្នុងគណនីរបស់អគ្គនាយកដ្ឋានពន្ធដារ ។ ជនជាប់ចោទបានធ្វើសកម្មភាពកិបកេងយកប្រាក់របស់ធនាគារច្រើនលើក ។ ហើយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជនជាប់ចោទបានយកប្រាក់ចេញពីធនាគារចំនួន ៦ ១៦០ ០០០ (ប្រាំមួយលានមួយសែនប្រាំមួយម៉ឺន)ដុល្លាអាមេរិក ច្រកក្នុងថង់ខ្មៅចំនួន ៣(បី) និងបានហៅជនជាប់ចោទឈ្មោះ [redacted] បញ្ញាសុជាតា ដែលជាអតីតបុគ្គលិកធនាគារកាណាឌីយ៉ា ក.អ ឱ្យមកជួយនាំសន្តិសុខ៣នាក់ ជញ្ជូនប្រាក់ឡើងទៅជាន់ទី៥ ប្រហែលជាកន្លះម៉ោងទើបឈ្មោះ [redacted] ស៊ីមន្តា ជាប្តីរបស់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ មកជញ្ជូនថង់ប្រាក់ទាំងនោះដាក់ក្នុងរថយន្តដឹកចេញទៅបាត់ ។ ជនជាប់ចោទពិតជាដឹងច្បាស់ថា គោលការណ៍ធនាគារមិនអនុញ្ញាតឱ្យបុគ្គលិកយកប្រាក់ចេញក្រៅទេ តែជនជាប់ចោទបែរជាយកប្រាក់ចេញក្រៅដោយក្នុងគោលបំណងកិបកេងយកប្រាក់នោះ ។ ការដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទអះអាងថា ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ យកប្រាក់ទៅប្តូរជាប្រាក់រៀលដើម្បីបានចំណេញក្បាលកាក់បន្តិចបន្តួចនោះ សបញ្ជាក់ឱ្យឃើញថា នៅធនាគារកាណាឌីយ៉ា ក.អ ក៏មានអត្រាប្តូរប្រាក់ដុល្លារមកជាប្រាក់រៀលដែរ ប៉ុន្តែជនជាប់ចោទកេងយកផលប្រយោជន៍ពីធនាគារយកមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនវិញ ។



Scanned with CamScanner

ម្យ៉ាងទៀត សកម្មភាពរបស់ជនជាប់ចោទ បានធ្វើឲ្យបាត់ទំនុកទុកចិត្តពីក្រសួងហិរញ្ញវត្ថុដែលផ្តល់ការងារឲ្យធនាគារ ដើម្បីស្វែងរកផលចំណេញពីអតិថិជនសម្រាប់ធនាគារផងដែរ ។ ភស្តុតាងទាំងអស់ត្រូវបានសាលាដំបូងរាជធានីភ្នំពេញលើកយកមកសំអាងហេតុសព្វគ្រប់ហើយ ។ មូលហេតុសាទុក្ខដែលលើកឡើងដោយមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក៏ដូចជាការឆ្លើយតបរបស់មេធាវីតំណាងឲ្យដើមបណ្តឹង តុលាការកំពូលពិចារណា ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការហើយ ដូចដែលសាលាដំបូងរាជធានីភ្នំពេញបានសំអាងហេតុចំណុចទី៣-ក និងទី៥ ដល់ទី២០ តុលាការកំពូលឯកភាពលើសំអាងហេតុនេះ ។ ភស្តុតាងទាំងអស់ដែលប្រមូលបានដែលអាចសន្និដ្ឋានបានថា ការដែលជនជាប់ចោទយកប្រាក់ចេញពីធនាគារដោយខុសនឹងគោលការណ៍របស់ធនាគារ និងការដែលជនជាប់ចោទយកប្រាក់ដុល្លារទៅប្តូរយកប្រាក់រៀលដើម្បីចំណេញក្បាលកាក់ ដែលខាងភាគីធនាគារមានអត្រាប្តូរយកប្រាក់រៀលដែរ តែជនជាប់ចោទមិនបានធ្វើការឲ្យធនាគារដោយសុចរិតនោះ គឺសុទ្ធតែក្នុងគោលបំណងកេងយកផលប្រយោជន៍ពីធនាគារដើម្បីបានមកជាប្រយោជន៍ដល់ខ្លួន ដែលធ្វើឲ្យភាគីធនាគារខាតបង់ប្រាក់ព្រមទាំងបាត់ជំនឿទុកចិត្តពីអតិថិជន ជាពិសេសពីក្រសួងហិរញ្ញវត្ថុ ។ ការដែលមេធាវីការពារជនជាប់ចោទបានអះអាងពីប្រាក់ដែលជនជាប់ចោទយកចេញក្រៅទៅប្តូរជាប្រាក់រៀលថា បានសងទៅធនាគារគ្រប់ចំនួនដែលមិនអាចឲ្យជនជាប់ចោទត្រូវមានកំហុសផ្នែកព្រហ្មទណ្ឌនោះ ក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះថា តាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា ។ ការដែលជនជាប់ចោទសងប្រាក់គ្រប់ចំនួនឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី គឺជាការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីត្រូវបានដោះស្រាយរួចមួយផ្នែក ដូចសាលាដំបូងបានសំអាងហេតុត្រង់ចំណុចទី៥៧ រួចស្រាប់ ។ ចំណែកការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជនជាប់ចោទនៅតែទទួលដដែលដូចបានសំអាងហេតុខាងលើ ។

ខ-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្តា បានលើកមូលហេតុសាទុក្ខថា ជនជាប់ចោទរូបនេះមិនជាប់ពាក់ព័ន្ធជាមួយប្រពន្ធរបស់គាត់ឈ្មោះ [redacted] វឌ្ឍននារីរតន៍ ទេ ហើយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១១ថ្ងៃត្រង់ ជនជាប់ចោទទៅទទួលប្រពន្ធចេញពីធនាគារដូចសព្វដង តែពេលនោះប្រពន្ធបានឲ្យជនជាប់ចោទទៅជួយយកថង់ខ្មៅមកដាក់ក្នុងឡាន ដោយជនជាប់ចោទមិនដឹងមានអ្វីទេ លុះមកដល់ក្នុងឡានទើបប្រពន្ធប្រាប់ថា ជាប្រាក់យកទៅប្តូរសម្រាប់បង់ពន្ធ តែជនជាប់ចោទមិនដឹងមានចំនួនប៉ុន្មានទេ ។ ចំពោះរូបភាពក្នុងទំព័រ១១ , ១២ , ១៣ ជារបស់ជនជាប់ចោទកាន់ស៊ីមីឯកសាររថយន្តដើម្បីយកទៅបង់ពន្ធរថយន្ត ឬអាចជាឯកសារវិក្កយបត្រដែលត្រូវយកទៅបង់ថ្លៃសាលារៀនកូន ។ ចំពោះរូបថតកាមេរ៉ា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ទំព័រទី៧, ៨ ជារូបរបស់ជនជាប់ចោទ និងប្រពន្ធនៅផ្ទះជាមួយគ្នា ហើយកាបូបជារបស់ប្រពន្ធដាក់អីវ៉ាន់ ចំពោះការប្រគល់ថង់គឺជាអីវ៉ាន់អនឡាញដែលប្រពន្ធឲ្យជនជាប់ចោទជួយយួរដើម្បីត្រឡប់ទៅផ្ទះ ពុំមានជាប់ពាក់ព័ន្ធជាមួយប្រាក់អតិថិជន ឬប្រាក់របស់ធនាគារទេ ។ តាមចម្លើយរបស់ឈ្មោះ [redacted] សុវណ្ណចរិយា ,ឈ្មោះ [redacted] សុឆាយ , ឈ្មោះ [redacted] រចនា , ឈ្មោះ [redacted] ហៀង ក៏បានបញ្ជាក់យ៉ាងច្បាស់



Scanned with CamScanner

លាស់ថា ពួកគាត់មិនដែលស្គាល់ និងមិនមានទំនាក់ទំនងអ្វីជាមួយឈ្មោះ [redacted]ស៊ីមន្តា ទេ ។ តាមការយល់ឃើញក្នុងសាលដីកាលេខ ១៦៤ " II " ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ របស់តុលាការកំពូលក៏បានបញ្ជាក់យ៉ាងច្បាស់ថា ឈ្មោះ[redacted]ស៊ីមន្តា ពុំមានចេតនាទុចរិត និងគែបំបាត់ប្រាក់ជាង ៦ ០០០ ០០០ (ប្រាំមួយលាន) ដុល្លារអាមេរិក នោះទេ ហើយព្យសនកម្មត្រូវបានដោះស្រាយរួចហើយ ។ ផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ, មាត្រា ៣៥០, មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ ។ ដូច្នេះសំណូមពរឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។ មូលហេតុសាទុក្ខដែលលើកឡើងដោយមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើនេះ តុលាការកំពូលពិនិត្យឃើញថា ភស្តុតាងដាក់បន្ទុកទាក់ទងនឹងអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីមន្តា ក្នុងបទសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ត្រូវបានសាលាដំបូងរាជធានីភ្នំពេញលើកយកមកសំអាងហេតុសព្វគ្រប់ដូចមានចំណុចទី៣-៦ ទី៧ បង្ហាញពីសកម្មភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ស៊ីមន្តា ជាអ្នកជញ្ជូនថង់ខ្មៅទាំង៣ថង់នោះចេញអស់នៅវេលាម៉ោង ១១និង ២០នាទីព្រឹក ហើយសំអាងហេតុទី៨ ជនជាប់ចោទឈ្មោះ[redacted] វឌ្ឍននារីរតន៍ ដែលត្រូវជាប្រពន្ធជនជាប់ចោទបានសារភាពថា ឈ្មោះ [redacted] ស៊ីមន្តា បានមកយកប្រាក់នោះដាក់ឡានដើម្បីយកទៅផ្ទះ និងសំអាងហេតុទី៤១, ទី៤២, ទី៥០ បង្ហាញពីការជួយសម្របសម្រួលដោយចេតនារបស់ជនជាប់ចោទ តុលាការកំពូលឯកភាពលើសំអាងហេតុទាំងអស់នេះ ។ ភស្តុតាងទាំងអស់នេះអាចចាត់ទុកបានថា ជនជាប់ចោទឈ្មោះ[redacted] ស៊ីមន្តា បានដឹងពិតប្រាកដនូវផែនការរបស់ប្រពន្ធ ហើយជាអ្នកជួយសម្រួលដោយផ្ទាល់ដល់ចារីឈ្មោះ [redacted] វឌ្ឍននារីរតន៍ ឱ្យប្រព្រឹត្តបានសម្រេចដូចមានបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។ ការដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើកឡើងពីសាលដីកាលេខ ១៦៤ "II" ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ របស់តុលាការកំពូលបញ្ជាក់យ៉ាងច្បាស់ថា ឈ្មោះ[redacted] ស៊ីមន្តា ពុំមានចេតនាទុចរិត និងគែបំបាត់ប្រាក់ជាង ៦ 000 000 (ប្រាំមួយលាន)ដុល្លារអាមេរិក ហើយព្យសនកម្មត្រូវបានដោះស្រាយរួចហើយនោះ សភាព្រហ្មទណ្ឌយល់ឃើញថា សំអាងហេតុនេះ តុលាការនៃបណ្តឹងសាទុក្ខនោះពិចារណាសម្រេចលើបណ្តឹងសាទុក្ខរបស់ជនត្រូវចោទ ពាក់ព័ន្ធទៅនឹងវិធានការនិរន្តរាយទាក់ទងនឹងមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន តាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះ ហើយក៏ពុំបានស៊ើជម្រៅលើមូលដ្ឋាននៃភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted]ស៊ីមន្តា ក្នុងរឿងអង្គសេចក្តីដូចបានសំអាងហេតុខាងលើនេះទេ ។

គ-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] សុវណ្ណចរិយា លើកឡើងនូវមូលហេតុសាទុក្ខថា ធនាគារអះអាងពីការបាត់ប្រាក់ត្រូវបានជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ សងទៅធនាគារគ្រប់ចំនួនហើយ ។ ចំណែកជនជាប់ចោទឈ្មោះ[redacted] សុវណ្ណចរិយា ជាអ្នកត្រួតពិនិត្យលើប្រព័ន្ធគណនីធនាគារនៅពេលដែលបេឡាករបានដាក់សាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារ ប៉ុន្តែបើបេឡាមិនបានបង់សាច់ប្រាក់ចូលក្នុងប្រព័ន្ធធនាគារទេ ជនជាប់ចោទឈ្មោះ[redacted]សុវណ្ណចរិយា មិនអាចដឹងឡើយ ។ ប្រសិនបើលុយចូលក្នុងប្រព័ន្ធធនាគារហើយ បើមានបាត់សាច់ប្រាក់សូម្បីតែ ១០០ រៀលខ្មែរ ទាំងបេឡាករ និងអ្នកត្រួតពិនិត្យត្រូវរកប្រាក់នោះឱ្យ



Scanned with CamScanner

ឃើញ ទើបការិយាល័យនោះអាចបិទបញ្ជីប្រចាំថ្ងៃបាន ដែលនេះជាគោលការណ៍ធនាគារ ។ ភស្តុតាងស្របគ្នាជាមួយចម្លើយដោះបន្ទុកដោយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ តុលាការថ្នាក់ក្រោមមិនជឿជាក់ដោយលើកយកមូលហេតុថា ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ជាអ្នកដោះសារឲ្យឈ្មោះ [redacted] សុវណ្ណចរិយា ទៅវិញ ។ ត្រង់ចំណុចនេះតុលាការមិនបានបង្ហាញភស្តុតាងណាមួយជាក់លាក់បង្ហាញពីធាតុអត្តនោម័ត និងធាតុសត្យានុម័តគ្រប់គ្រាន់ ដែលនាំឲ្យតុលាការជឿលើចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍន-នារីរតន៍ ឡើយ ដូចមានសំអាងហេតុចំណុចទី២៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។ សំណូមពរសម្រេចឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។ មូលហេតុសាទុក្ខដែលលើកឡើងដោយមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញបានសំអាងហេតុត្រង់ចំណុចទី៣-ខ, ទី២៨ , ទី២៩, ទី៣០, ទី៣១, ទី៣៩, ទី៤០ តុលាការកំពូលឯកភាពលើសំអាងហេតុទាំងនេះ ។ ជនជាប់ចោទពិតជាបានដឹងយ៉ាងច្បាស់ពីសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ប៉ុន្តែបុគ្គលរូបនេះបានលាក់បំបាំងដោយមិនរាយការណ៍ប្រាប់ថ្នាក់លើរបស់ខ្លួន ដែលការនេះអាចសន្និដ្ឋានបានថា ជនជាប់ចោទពិតជាមានចេតនាព្រមព្រៀងសហការគ្នាជាមួយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ហើយ ។

ឃ-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុផាយ លើកឡើងនូវមូលហេតុសាទុក្ខថា កូនក្តីខ្លួនឈ្មោះ [redacted] សុផាយ សាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍មិនមានភស្តុតាងដើម្បីបញ្ជាក់ថាកូនក្តីជាអ្នកសមគំនិតជាមួយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដើម្បីយកប្រាក់ចេញពីធនាគារទេ ។ ជនជាប់ចោទឈ្មោះ [redacted] សុផាយ គ្រាន់តែដើរទៅជួបប្រពន្ធឈ្មោះ [redacted] សុវណ្ណចរិយា ក្នុងការិយាល័យធ្វើការដើម្បីជូនបាយ ឬរបស់ញ៉ាំ គ្មានអ្វីទាក់ទងនឹងការយកប្រាក់ចេញឡើយ ។ ជនជាប់ចោទឈ្មោះ ថោង សុផាយ មិនមានតួនាទីធំដែលអនុញ្ញាតឲ្យចូលក្នុងប្រព័ន្ធធនាគារដើម្បីលុបទិន្នន័យ ឬផ្ទេរគណនី ឬផ្ទេរសាច់ប្រាក់ណាមួយបានឡើយ ។ ជនជាប់ចោទរូបនេះក៏គ្មានសមត្ថភាពធ្វើរឿងនឹងដែរ ពីព្រោះថា នៅក្នុងធនាគារមានការបែងចែកការងារដាច់ពីគ្នារវាងអ្នកជួសជុល អ្នកថែរក្សា Server អ្នកត្រួតពិនិត្យប្រព័ន្ធប្រតិបត្តិកុំព្យូទ័រជាដើម ។ ប៉ុន្តែតួនាទីជនជាប់ចោទគ្រាន់តែជាអ្នក IT ធម្មតាប៉ុណ្ណោះ ។ ដូច្នេះដើមបណ្តឹង និងតុលាការពុំមានភស្តុតាងចង្អុលបង្ហាញថា ឈ្មោះ [redacted] សុផាយ បានលុកលុយចូលក្នុងប្រព័ន្ធប្រតិបត្តិការណ៍ធនាគារដើម្បីធ្វើការផ្លាស់ប្តូរ លួច ឬផ្ទេរប្រាក់ចេញពីគណនីរបស់បុគ្គលណាមួយ ឬពីធនាគារមួយទៅក្នុងគណនីខ្លួនឡើយ ។ មូលហេតុសាទុក្ខនេះ តុលាការកំពូលពិនិត្យឃើញថា សំអាងហេតុរបស់សាលាដំបូងរាជធានីភ្នំពេញចំណុចទី៣-ឃ, ទី៤៣ , ទី៤២ និងតាមការបង្ហាញពីដើមបណ្តឹងថា ជនជាប់ចោទឈ្មោះ [redacted] សុផាយ ជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា និងជាប្រធានក្រុមប្រព័ន្ធស្នូលធនាគារនៅស្នាក់ការកណ្តាលដែលដឹងច្បាស់ពីប្រព័ន្ធគ្រប់គ្រងធនាគារ ពិសេសកិច្ចប្រតិបត្តិការបង់ពន្ធនៅការិយាល័យបង់ពន្ធ ។ ជនជាប់ចោទតែងតែចេញចូលញឹកញាប់នៅបន្ទប់បង់ពន្ធ ហើយក៏ធ្លាប់ពិនិត្យមើលប្រព័ន្ធបង់ពន្ធនៅពេលដែលដំណើរការរអាក់រអួល ។ ដូច្នេះពិតជាស្គាល់ច្បាស់ពីប្រតិបត្តិការបង់ពន្ធ ស្គាល់ពីកង្វះចន្លោះប្រហោងក្នុងប្រតិបត្តិការបង់ពន្ធ ដែលអាចលួចយក



Scanned with CamScanner

ប្រាក់ពន្ធបាន ជាពិសេសការបោះពុម្ពបង្កាន់ដៃបង់ពន្ធ និងការមិនដាក់ប្រាក់ចូលក្នុងគណនីពន្ធដារនៅធនាគារជាដើម ។ ភស្តុតាងទាំងអស់ធ្លួនល្មមអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោ [redacted] សុឆាយ ពិតជាបានព្រមព្រៀងសហការគ្នាជាប្រព័ន្ធជាមួយជនជាប់ចោទជាមួយគ្នាដើម្បីគេចបំបាត់ប្រាក់ពន្ធហើយ ។

ង-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ក៏ដូចជាជនជាប់ចោទឈ្មោះ [redacted] រចនា លើកឡើងពេលសវនាការថា មូលហេតុប្តឹងសាទុក្ខមកតុលាការកំពូលដោយហេតុថា ការចោទប្រកាន់លើឈ្មោះ [redacted] រចនា ពីបទសមគំនិតដោយសារជនជាប់ចោទជាអនុប្រធានទទួលបន្ទុកផ្នែកទទួលប្រាក់ពន្ធ ហើយពាក្យបណ្តឹងគ្រប់ដំណាក់កាលរបស់មេធាវីពុំបានប្តឹងចំឈ្មោះជនជាប់ចោទនេះទេ ។ ហើយអង្គហេតុកើតឡើងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជាថ្ងៃដែលកូនក្តីខ្លួនបានសុំច្បាប់ឈប់សម្រាក និងតាមការសួរបញ្ជាក់ពីមេធាវីតំណាងឱ្យធនាគារថា កូនក្តីខ្លួនឈ្មោះ [redacted] រចនា ពិតជាបានសុំច្បាប់ឈប់សម្រាកពិតប្រាកដមែន។ អង្គហេតុនេះចោទប្រកាន់មិនពាក់ព័ន្ធជាមួយជនជាប់ចោទទេ វាល់ចម្លើយសារភាពរបស់ជនជាប់ចោទដែលពាក់ព័ន្ធក៏មិនឆ្លើយដាក់បន្ទុកឈ្មោះ [redacted] រចនា ដែរ ។ តាមខ្លឹមសារមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ឈ្មោះ [redacted] រចនា ពុំបានប្រព្រឹត្តបទសមគំនិតឡើយ ។ ក្រោយពីដឹងថា មានបញ្ហាកើតឡើងភ្លាម ឈ្មោះ [redacted] រចនា ក្នុងនាមជាប្រធានគ្រប់គ្រង មានតួនាទីត្រួតពិនិត្យទៅលើកូនចៅគាត់ពេលដែលទទួលប្រាក់ពីអតិថិជនរួចបញ្ចូលប្រាក់ទាំងអស់ចូលទៅក្នុង System របស់ធនាគារកាលណាឌីយ៉ា ទើបកូនក្តីខ្លួនអាចត្រួតពិនិត្យក្នុង System បាន ។ ករណីនេះឈ្មោះ [redacted] រចនា មិនបានចូលរួមប្រព្រឹត្តឡើយ គឺមានតែធ្វើការលួងលោមឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដើម្បីឱ្យឈ្មោះនេះយកប្រាក់ទាំងអស់មកដាក់ក្នុងធនាគារគ្រប់ចំនួនវិញប៉ុណ្ណោះ ។ សំណូមពរតុលាការកំពូលសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] រចនា រួចខ្លួនពីបទចោទប្រកាន់ ។ មូលហេតុសាទុក្ខដែលលើកឡើងដោយភាគីជនជាប់ចោទឈ្មោះ [redacted] រចនា តុលាការកំពូលផ្អែកលើសំអាងហេតុរបស់សាលាដំបូងចំណុចទី៣-គ, ទី១០, ទី២៥ ,ទី២៨ ,ទី២៩ ដល់ទី៣៨ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] រចនា ពិតជាបានចូលរួមយ៉ាងសកម្មជាមួយជនជាប់ចោទផ្សេងទៀតជាពិសេស ជាមួយជនជាប់ចោទឈ្មោះ [redacted] វឌ្ឍននារីរតន៍ ដោយផ្ទាល់តែម្តង ។ ចំពោះការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ក៏ដូចជាជនជាប់ចោទលើកឡើងថា មិនបានចូលរួមប្រព្រឹត្តមានតែលួងលោមជនជាប់ចោទឈ្មោះ [redacted] ឌ្ឍននារីរតន៍ ដើម្បីឱ្យឈ្មោះនេះយកប្រាក់ទាំងអស់មកដាក់ក្នុងធនាគារគ្រប់ចំនួនវិញនោះ មិនមានភស្តុតាងទេ ។ ឯការដែលជនជាប់ចោទ ក៏ដូចជាមេធាវីការពារសិទ្ធិលើកឡើងថា អង្គហេតុកើតឡើងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ជាថ្ងៃដែលជនជាប់ចោទបានសុំច្បាប់ឈប់សំរាក ដូចដែលមេធាវីតំណាងដើមបណ្តឹងទទួលស្គាល់ដែរ ដែលមិនជាប់ពាក់ព័ន្ធការយកប្រាក់ចេញនោះ តុលាការកំពូលពិនិត្យឃើញថា ជាក់ស្តែងបើទោះជនជាប់ចោទមានការឈប់សម្រាកមែន ប៉ុន្តែសកម្មភាពរវាងជនជាប់ចោទជាមួយជនជាប់ចោទផ្សេងទៀត ពិសេសសកម្មភាពជាមួយជនជាប់ចោទឈ្មោះ [redacted] ឌ្ឍននារីរតន៍ នៅតែមានទំនាក់ទំនងគ្នាយ៉ាងសកម្មដូចបានលើកឡើងពីសំអាងហេតុរបស់សាលាដំបូងខាងលើស្រាប់ ។



Scanned with CamScanner

ច-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក៏ដូចជាជនជាប់ចោទឈ្មោះ [redacted] ហៀង លើកឡើងនូវមូលហេតុសាទុក្ខថា តាមអង្គហេតុ អង្គច្បាប់ និងភស្តុតាងសបញ្ជាក់ឲ្យឃើញថា សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ហៀង ជាសន្តិសុខបានធ្វើសកម្មភាពបម្រើការងារនៅក្នុងរង្វង់សមត្ថកិច្ចរបស់ពួកគាត់តែប៉ុណ្ណោះ គឺជួយលើកដាក់ជញ្ជូនអីវ៉ាន់តាមការពឹងពាក់ពីបុគ្គលិករបស់ធនាគារ ហើយគាត់ពុំមានសិទ្ធិសួរនាំពីអ្វីដែលមានក្នុងថង់ទាំងបីនោះដែរ ពីព្រោះថា ធនាគារជាទីកន្លែងលាក់ការសម្ងាត់បំផុត ។ ដូច្នេះការចោទប្រកាន់ឈ្មោះ[redacted]ហៀង ពីបទសមគំនិតក្នុងអំពើរំលោភលើទំនុកចិត្តពិសេសដោយអភិបាល ឬបុគ្គលផ្សេងទៀត ជាការចោទប្រកាន់ពុំមានទទ្បីករណ៍ឡើយ ។ សំណូមពរសម្រេចសេចក្ដីឲ្យជនជាប់ចោទឈ្មោះ[redacted]ហៀង រួចខ្លួនពីបទចោទប្រកាន់ចាប់ពីពេលនេះតទៅ ។ មូលហេតុសាទុក្ខនេះ តុលាការកំពូលពិចារណាឃើញថា សំអាងហេតុរបស់សាលាដំបូងរាជធានីភ្នំពេញចំណុចទី៣-៦, ទី៧ ដល់ទី៩, ទី១៩ , ទី២០ ដល់ទី២៤ បានលើកឡើងពីភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់សម្រាប់ដល់ការវិនិច្ឆ័យសេចក្ដីចំពោះជនជាប់ចោទឈ្មោះ [redacted]ហៀង តាមមាត្រា ២៩ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌហើយ តុលាការកំពូលឯកភាពលើសំអាងហេតុនេះ ដោយពុំចាំបាច់លើកយកមកសំអាងជាថ្មីម្ដងទៀតទេ ។

៤-យល់ឃើញថា មូលហេតុនៃបណ្ដឹងសាទុក្ខដែលលើកឡើងដោយមេធាវីការពារសិទ្ធិជនជាប់ចោទ ក៏ដូចជាជនជាប់ចោទទាំងអស់ពុំចូលត្រង់ចំណុចណាមួយនៃបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ដែលគប្បីសម្រេចបដិសេធបណ្ដឹងសាទុក្ខនេះចោលទាំងស្រុង និងសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ តាមបញ្ញត្តិមាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និថា សាលដីកាព្រហ្មទណ្ឌរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញសម្រេចសេចក្ដី ដោយមានទទ្បីករណ៍នៃអង្គហេតុ និងអង្គច្បាប់ត្រឹមត្រូវហើយ ស្នើសុំតម្កល់សាលដីកានេះទុកជាបានការ នោះគឺជាសេចក្ដីសន្និដ្ឋានដែលតុលាការកំពូលឯកភាព និងទទួលយកបាន ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសំអាងហេតុត្រង់ចំណុចទី៨ ថា សាលក្រមព្រហ្មទណ្ឌលេខ ១១១៨ "ល" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចសេចក្ដីមកមានលើកសំអាងហេតុសព្វគ្រប់ និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គួរសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ពិចារណា និងសម្រេចតម្កល់ទុកជាបានការតាមច្បាប់នោះ ឃើញថា សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បានពិចារណា និងសម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ។



Scanned with CamScanner

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១. បដិសេធបណ្តឹងលេខ ៣៩៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] សុគន្ធ ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោ[redacted] ស៊ីមន្ថា និងឈ្មោ[redacted]វឌ្ឍននារីរតន៍ ក្នុងការប្តឹងសាទុក្ខ, បណ្តឹងលេខ ៤២៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ប៊ុនធឿន ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឱ្យជនជាប់ចោទឈ្មោះ [redacted] សុឆាយ និងឈ្មោះ [redacted] សុវណ្ណចរិយា ក្នុងការប្តឹងសាទុក្ខ, បណ្តឹងសាទុក្ខលេខ ៤០៣ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោ[redacted]ហៀង និងបណ្តឹងសាទុក្ខលេខ ៤២១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]រចនា ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រI.សវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ និងប្រកាសនៅសាលសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។

ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

**បានឃើញ**

ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner

"យើង ស៊ីវ គឹមម៉ិច ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះបានចូលជាស្ថាពរ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ និងមានអានុភាពអនុវត្តតាមច្បាប់ ។"

"សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់ មក[illegible] អនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ថ្នាក់ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។"

ថ្ងៃសុក្រ ១៣រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២

ក្រឡាបញ្ជី

ស៊ីវ គឹមម៉ិច

Scanned with CamScanner